**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦១ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់ប្រាក់ខ្វាន់លើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូល ពីតម្លៃសេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីសម្រេចលេខ១១៩ សសរ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័នប្រមូលចំណូល សម្រាប់ការផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ..១៣០...... សហវ.ប្រក ចុះថ្ងៃទី..១៧.. ខែ..ធ្នូ... ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍
- យោងតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍ សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតលើការបម្រើសេវាសាធារណៈ និងការពិន័យជាប្រាក់ ព្រមទាំងចំណាយពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .-**

ក្រសួងទេសចរណ៍ ត្រូវបង់ថវិកា ១% នៃចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (មូលនិធិ ក.ហ.ស) ដោយអនុលោមតាមសារាចរលេខ ០០៤ សហវ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង់ថវិកាចំណូលមិនមែនសារពើពន្ធចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣ .-**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងអនុវត្តដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត។

**ប្រការ៤ .‒**

អនុញ្ញាតឱ្យរដ្ឋបាលកណ្ដាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត បុរេប្រទានប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស ពីចំណូលដែលប្រមូលបានរៀងៗខ្លួន ពីកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់។

រដ្ឋបាលកណ្ដាលក្រសួងទេសចរណ៍ ត្រូវបុរេប្រទានចំណែកប្រាក់រង្វាន់របស់ក្រសួងទេសចរណ៍, ចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចំណែកថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស។

មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវបុរេប្រទានចំណែកប្រាក់រង្វាន់របស់មន្ទីរទេសចរណ៍ និងចំណែកប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥ .‒**

ការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែកដូចខាងក្រោម ÷

| បរិយាយ | អត្រារង្វាន់លើចំណូលប្រមូលបាន |
|---|---|
| I. <u>ការបែងចែកចំណូលដែលប្រមូលដោយរដ្ឋបាលកណ្ដាល</u> | |
| ១. ចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈ | |
| - បង់ចូលថវិកាជាតិ | ៤៩% |
| - ថវិកាគាំទ្រមូលនិធិ ក.ហ.ស | ១% |
| - ប្រាក់រង្វាន់របស់ក្រសួងទេសចរណ៍ | ៤៩% |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% |
| ២. ចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ជាប្រាក់ | |
| - បង់ចូលថវិកាជាតិ | ៤៩% |
| - ថវិកាគាំទ្រមូលនិធិ ក.ហ.ស | ១% |
| - ប្រាក់រង្វាន់របស់ក្រសួងទេសចរណ៍ | ៤៩% |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% |
| II. <u>ការបែងចែកចំណូលដែលប្រមូលដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត</u> | |
| ១. ចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈ | |
| - បង់ចូលថវិកាជាតិ | ៥០% |
| - ប្រាក់រង្វាន់របស់មន្ទីរទេសចរណ៍ | ៤៩% |
| - ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% |

| | |
|---|---|
| ២. ចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ជាប្រាក់ | |
| - បង់ចូលថវិកាជាតិ | ៥០% |
| - ប្រាក់រង្វាន់របស់មន្ទីរទេសចរណ៍ | ៤៩% |
| - ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% |
| III- **ករណីចំណូលប្រមូលបានពីការផ្តន្ទាទោសពិន័យជាប្រាក់ដែលអនុវត្តតាមការសម្រេចរបស់សាលាជម្រះក្តី** | |
| - បង់ចូលថវិកាជាតិ | ២៥% |
| - ថវិកាគាំទ្រមូលនិធិ ក.ហ.ស | ១% |
| - ប្រាក់រង្វាន់របស់សាលាជម្រះក្តីពាក់ព័ន្ធ | ២៤% |
| - ប្រាក់រង្វាន់របស់ក្រសួងទេសចរណ៍ | ៤៩% |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% |

**ប្រការ៦ .-**

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងឥណទានចំណាយប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ ត្រូវគ្រោងឥណទានចំណាយប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស។

មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវគ្រោងឥណទានចំណាយប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

ឥណទានប្រាក់រង្វាន់ដែលបានគ្រោង ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការចំណាយប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្តដែរ។

**ប្រការ៧ .-**

ការទូទាត់ប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

**ក. ផ្នែកចំណូល**

ធ្វើសលាកបត្របង់ចំណូលថវិកាជាតិដោយចុះចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងធ្វើសំណើសុំកត់ត្រាចំណូល ÷

- **ចំពោះរដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ :** បញ្ជូនសំណើ និងសលាកបត្របង់ចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវតារាងគណនាប្រាក់រង្វាន់, តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់, របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ ដែលបានបើកផ្តល់កន្លងមក។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

- **ចំពោះមន្ទីរទេសចរណ៍រាជធានី ខេត្ត :** បញ្ជូនសំណើ និងសលាកបត្របង់ចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវតារាងគណនាប្រាក់រង្វាន់, តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់, របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ ដែលបានបើកផ្តល់កន្លងមក។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

**ខ. ផ្នែកចំណាយ**

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវធ្វើសំណើសុំទូទាត់ប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រដល់មូលនិធិ ក.ហ.ស និងធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

**ប្រការ៨ .-**

ការបើកផ្តល់ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃសាលាជម្រះក្តី និងមន្ត្រីពាក់ព័ន្ធ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៩ .-**

ត្រូវបាននិរាករណ៍ប្រកាសរួម ដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៩៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ប្រកាសរួមលេខ ២៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្តល់ថវិការង្វាន់លើកទឹកចិត្ត លើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២០ តទៅ។

ថ្ងៃ ... ខែ ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ